# របាយការណ៍ប្រចាំត្រីមាសទី៣

(ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី៣ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---:|---:|
| ទ្រព្យសកម្មសរុប | ៤.០៦៤.៣៤៣ | ៤.០១៥.០៤១ |
| បំណុលសរុប | ៣.២៧៩.០០៨ | ៣.៣០៦.៨១៧ |
| មូលធនសរុប | ៧៨៥.៣៣៥ | ៧០៨.២២៤ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី៣ឆ្នាំ២០២២** | **ត្រីមាសទី៣ឆ្នាំ២០២១** |
| ចំណូលសរុប | ៨២.៣៨២ | ៧៨.៥៦១ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ៣១.៣៩៩ | ២៧.៦០៣ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ២៥.២០៦ | ២១.៨៧២ |
| លទ្ធផលម្អិតក្នុងការិយបរិច្ឆេទ | ២៩.០២៤ | ២២.៥០៣ |
| **អនុបាតហិរញ្ញវត្ថុ(%)** | **ត្រីមាសទី៣ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព ● | ២១,៣២ | ១៩,១៩ |
| អនុបាតបំណុលធៀបនឹងមូលធន | ៤១៧,៥៣ | ៤៦៦,៩២ |
| អនុបាតគ្របខ័ណ្ឌសន្ទនីយភាព ❶ | ១១១,៦៥ | ១២៥,៤៦ |
| អនុបាតឥណទានមិនដំណើរការ ❷ | ៤,៧៥ | ១,៨២ |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ១០៤,២០ | ៩៧,០៨ |
| **អនុបាតផលចំណេញ(%)** | **ត្រីមាសទី៣ឆ្នាំ២០២២** | **ត្រីមាសទី៣ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) | ២,៨៣ | ២,១៣ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) | ១៤,៦៦ | ១៣,០២ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៩៣៥,៦៦ | ៨១៥,១៥ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | មិនមាន | មិនមាន |

សំគាល់ :

❶ : អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជា

❷ : ឥណទានមិនដំណើរការអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

សមាជិក



**Kim, Sung Chul**

សមាជិក



**HONG, Jee Soo**

សមាជិកឯករាជ្យ



**LEE, Myunsang**

សមាជិកឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំង ក្នុងការបង្ហាញជូននូវប្រតិបត្តិការហិរញ្ញវត្ថុ របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ដោយអនុវត្តតាមតម្រូវការរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក) ។

ជំងឺរាតត្បាតកូវីដ-១៩ បានអូសបន្លាយឆ្នាំ២០២១ អោយក្លាយជាឆ្នាំដ៏លំបាកសម្រាប់ពិភពលោក និងកម្ពុជា ដែលមិនអាចទាយទុកជាមុនបានឡើយ ជាពិសេសព្រឹត្តិការណ៍រាតត្បាតសហគមន៍នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការការពារសង្គម និងសេដ្ឋកិច្ចជាមួយនិង ការកើនឡើងយ៉ាងឆាប់រហ័សនៃការចាក់វ៉ាក់សាំង ក៏ដូចជាវិធានការអនុវត្តដ៏រឹងមាំ តាមរយៈការផ្តល់នូវការអនុវត្តវិធានការបង្ការ និងភាពជោគជ័យនៃការចាក់វ៉ាក់សាំង កូវីដ១៩ ដែលគ្របដណ្តប់ជាង ៩០% នៃចំនួនប្រជាជនសរុបដែលជាមូលហេតុអនុញ្ញាតឱ្យមានការបន្ធូរបន្ថយ ការរឹតបន្តឹងការធ្វើដំណើរ និងធ្វើឱ្យប្រទេសបើកដំណើរការឡើងវិញសម្រាប់ការស្តារសេដ្ឋកិច្ចរបស់ខ្លួន។

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរក្សាការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ខ្លួនសម្រាប់ប្រទេសកម្ពុជានៅកម្រិត ៥.៣% ក្នុងឆ្នាំ ២០២២ ប៉ុន្តែបានបន្ទាបការព្យាករណ៍ក្នុងឆ្នាំ២០២៣ មកនៅត្រឹម ៦.២% ពី ៦.៥% ដោយមូលហេតុនៃកំណើនសេដ្ឋកិច្ចពិភពលោកចុះខ្សោយ ។ ទិន្នផលសម្លៀកបំពាក់ បូករួមទាំងទំនិញទេសចរណ៍ និងទិន្នផលស្បែកជើងរបស់កម្ពុជានៅតែបន្តរឹងមាំហើយបានចុះបញ្ជីកំណើន ៣៩.៨% ពីមួយឆ្នាំទៅមួយឆ្នាំក្នុងឆមាសទីមួយនៃឆ្នាំ២០២២ ទោះបីជាសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក និងអឺរ៉ុបធ្លាក់ចុះក៏ដោយ។ វិស័យផលិតកម្មមិនមែនកាត់ដេរបានកំពុងនិងបន្តសន្ទុះកំណើនរបស់ខ្លួនយ៉ាងខ្លាំង។ វិស័យសំណង់បានងើបឡើងវិញជាបន្តបន្ទាប់ដោយការនាំចូលសម្ភារសំណង់កើនឡើង ២២,៨%។

បើទោះបីជាយើងបានប្រឈមជាមួយពេលវេលាដ៏លំបាកនេះក៏ដោយ ក៏នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតនូវសេវាកម្មថ្មីមួយស្តីពីសេវាផ្ទេរប្រាក់អន្តរជាតិតាមប្រព័ន្ធបាគង ពីប្រទេសកូរ៉េ (ខាងត្បូង) មកកម្ពុជាជាមួយការទូទាត់ភ្លាមៗ ដែលបានអនុវត្តជាផ្លូវការ ចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២។ នៅក្នុងខែសីហា យើងបានកែលម្អ

សេវាធនាគារចល័ត (PPCBank Mobile Banking) ដែលបានបន្ថែមអោយ សេវាខេអេចយូអរ ផ្ទេរចេញជារូបភាពឃ្យូអរ សម្រាប់ប្រើប្រាស់បានទាំងក្នុង សេវាធនាគារ ចល័ត និងអតិថិជនរបស់ធនាគារដែលជាម្ចាស់អាជីវកម្ម ក្នុងគោលបំណងធ្វើការចែករំលែកទៅកាន់អ្នកប្រើប្រាស់ធនាគារផ្សេងទៀតដើម្បីទូទាត់បានយ៉ាងងាយស្រួល ។ ហើយនៅ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាប្រមូលការទូទាត់តាមគណនីនិម្មិត ដើម្បីទទួលបានការទូទាត់ភ្លាមៗតាមរយៈបាគង។ លើសពីនេះទៅទៀត នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២ យើងក៏បានអនុវត្តការទូទាត់វិក្កយប័ត្របង់ទឹក PPWSA (រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ) និង វិក្កយប័ត្របង់ភ្លើង EDC (អគ្គិសនីកម្ពុជា) នៅលើសេវាធនាគារតាមអ៊ីនធើណែត (Corporate Internet Banking) ដោយមិនគិតថ្លៃផងដែរ ។

ក្នុងនាមតំណាងក្រុមប្រឹក្សាភិបាល ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណចំពោះភាគទុនិកក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ និងក៏ដូចជាបុគ្គលិករបស់យើងដែលបានខិតខំប្រឹងប្រែង សម្រាប់ការរួមចំណែកនិងការប្តេជ្ញាចិត្តរបស់ពួកគាត់ និងអរគុណចំពោះអតិថិជនដ៏មានតម្លៃរបស់យើងសម្រាប់ការបន្តការជឿទុកចិត្តរបស់ពួកគេមកលើធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងនិយ័តករមូលប័ត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និងការគាំទ្រ ។

ខ្ញុំ Yim Yong Taick សូមសម្តែងនូវការដឹងគុណចំពោះការខិតខំប្រឹងប្រែងដែលទទួលបានលទ្ធផលជោគជ័យក្នុងអំឡុងត្រីមាសទី ៣ ឆ្នាំ ២០២២ និងបន្តឆ្ពោះទៅរកអ្វីដែលយើងនឹងសម្រេចបាននៅក្នុងត្រីមាសខាងមុខជាបន្តបន្ទាប់ ។

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២

ហត្ថលេខា និងត្រា

YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** .......... 1

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** .......... 2

**សមាសភាពក្រុមប្រឹក្សាភិបាល** .......... 3

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** .......... 4

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** .......... 7

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ .......... 7

ខ. លក្ខណៈនៃធុរកិច្ច .......... 8

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ .......... 9

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** .......... 11

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក .......... 11

ខ. រចនាសម្ព័ន្ធចំណូល .......... 11

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** .......... 12

**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** .......... 13

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ .......... 13

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ .......... 15

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល .......... 18

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ .......... 18

ង. ផលប៉ះពាល់អតិផរណា .......... 18

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល .......... 18

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** .......... 19

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | **Phnom Penh Commercial Bank Plc.** |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម<br>សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/(+៨៥៥) ២៣ ៩៩៩ ៥០០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៩២/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០១កញ្ញា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Baek Jongil |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្តើមប្រតិបត្តិការធនាគារ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្តើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំ គឺ Jeonbuk Bank Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.), ក្រុមហ៊ុន Apro Financial Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co., Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co., Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀតយើងក៏មិនភ្លេច និងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើងគាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមបំណាច់ ខែកញ្ញា ឆ្នាំ២០២២ ទ្រព្យសកម្មសរុបមានចំនួន ៩៨៧ លានដុល្លារអាមេរិក និងមានសាខា២៣ទូទាំងប្រទេស និងម៉ាស៊ីន ATMs ចំនួន៧០ (ម៉ាស៊ីនATMsផ្សេងៗទៀតកំពុងត្រូវបានពិចារណានៅទីតាំងសក្តានុពលក្នុងប្រទេសកម្ពុជា)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងបន្តធ្វើការផ្តល់ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្តាញឌីជីថលដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួល ជាមួយនិងបទពិសោធន៍ធនាគារ។ អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ Live Chat ក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ លើសពីនេះទៅទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតមជ្ឈមណ្ឌលសហគ្រាសធុនតូច-មធ្យម (SME Center) ជាលើកដំបូងរបស់ខ្លួន ដែលនឹងផ្តល់នូវផលិតផល និងសេវាSME។ សហគ្រាសធុនតូច-មធ្យម នឹងត្រូវទទួលបាននូវសេវាពិគ្រោះយោបល់អាជីវកម្មផងដែរ។ ពួកយើង

ក៏បានពង្រីកនូវការិយាល័យបរទេស (Foreign Desk) មានដូចជា ការិយាល័យកូរ៉េ ជប៉ុន និងចិន ក៏ដូចជា ហ្គោលក្លឹប និងមជ្ឈមណ្ឌល SME ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផលសេវារបស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

នៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសម្រេចធ្វើការផ្លាស់ប្តូរទីតាំងសាខាខេត្ត សៀមរាបដោយទទួលបានការអនុញ្ញាតពីធនាគារ ជាតិ នៃ កម្ពុជា ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ និងទទួលបានការអនុញ្ញាតពី ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០២២។

ដើម្បីផ្តល់នូវភាពងាយស្រួលជូនដល់អតិថិជនដ៏មានតម្លៃរបស់យើង ក៏ដូចជាដើម្បីពង្រីកសកម្មភាពប្រតិបត្តិការរបស់ខ្លួន ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសម្រេចធ្វើការផ្លាស់ប្តូរទីតាំងសាខាទឹកថ្លា ដោយកំពុងដំណើរការដើម្បីទទួលបានការយល់ព្រមពីធនាគារជាតិ នៃ កម្ពុជា (NBC) ។

ដោយសារយើងជាធនាគារ ដែលផ្តោតលើភាពងាយស្រួល ដូច្នេះទើបយើងខិតខំប្រឹងប្រែងនាំយកអ្វីដែលប្រសើរ និងមានភាពងាយស្រួលសម្រាប់អតិថិជន អោយកាន់តែទទួលបានអារម្មណ៍ប្រសើរឡើង ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតនូវសេវាកម្មថ្មីមួយស្តីពី សេវាផ្ទេរប្រាក់អន្តរជាតិ ពីប្រទេសកូរ៉េ (ខាងត្បូង) មកកាន់ប្រទេសកម្ពុជា តាមរយៈសមាជិកបាគងទាំងអស់ ដែលធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសហការជាមួយធនាគារ Jeonbuk ដើម្បីអនុញ្ញាត/បើកការផ្ទេរប្រាក់ពីធនាគារ Jeonbuk ទៅកាន់សមាជិកបាគងទាំងអស់ជាមួយការទូទាត់ភ្លាមៗ។ តបតាមការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ក្នុងអតិថិជនម្នាក់អាចផ្ទេរប្រាក់បានរហូតដល់ ១០,000 ដុល្លារក្នុងមួយថ្ងៃ តាមរយៈសេវាកម្មនេះ ។ ការផ្ទេរប្រាក់អាចធ្វើឡើងពីធនាគារចល័តរបស់ Jeonbuk Mobile Banking សេវាធនាគារតាមអ៊ីនធើណែត និងតាមរយៈសាខាផ្ទាល់។ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក គឺជាធនាគារដំបូងគេនៅក្នុងប្រទេសកម្ពុជាដែលទទួលបានការសហការជាមួយធនាគារ Jeonbuk ក្នុងការអនុញ្ញាតអោយមានការផ្ទេរប្រាក់

ពីប្រទេសកូរ៉េខាងត្បូងជាមួយការទូទាត់ភ្លាមៗទៅកាន់សមាជិកបាគង ទាំងអស់នៅក្នុងប្រទេសកម្ពុជា តាមរយៈសេវាផ្ទេរប្រាក់បាគង។

ពីមួយខែទៅមួយខែ យើងកំពុងបន្តធ្វើឱ្យប្រសើរឡើងសម្រាប់ការកែលម្អ ដូច្នេះហើយទើប នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ សេវាធនាគារចល័តរបស់ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់បញ្ចូលនិងដាក់អោយអនុវត្ត នូវមុខងារបន្ថែមរបស់ ឃេអេចឃ្យូអរ ដែលអាចទាញយកជារូបភាព ឃេអេចឃ្យូអរ សម្រាប់ប្រើប្រាស់ក្នុងការទូទាត់រវាងគណនីនៃធនាគារពីរផ្សេងគ្នាតាមរយៈឃ្យូអរ ដោយភាគីទាំងសងខាង មិនចាំបាច់ជួបគ្នាផ្ទាល់ដើម្បីធ្វើការទូទាត់នោះទេ។ សម្រាប់ទាំងអ្នកប្រើប្រាស់សេវាធនាគារចល័ត និងទាំងម្ចាស់អាជីវកម្ម គឺអាចទាញយក ឃេអេចឃ្យូអររបស់ធនាគារយើងដើម្បីចែករំលែកបានយ៉ាងងាយស្រួល។

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រេចបាន កាន់តែប្រសើរឡើងនូវការដាក់អោយប្រើប្រាស់ សេវាប្រមូលការទូទាត់តាមគណនីនិម្មិត ដើម្បីទទួលបានការទូទាត់ភ្លាមៗតាមរយៈបាគង។ អតិថិជន និងសហគ្រាសដែលប្រើប្រាស់គណនីនិម្មិតរបស់យើង ជាការប្រមូលការទូទាត់សម្រាប់អាជីវកម្មរបស់ពួកគេអាចទទួលបានការទូទាត់ពីសមាជិកបាគងជាច្រើន ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ការទូទាត់វិក្កយប័ត្របង់ទឹក PPWSA និង ការទូទាត់វិក្កយប័ត្របង់ភ្លើង EDC បានដាក់អោយដំណើរការតាមប្រព័ន្ធអ៊ីនធើណែត និងដោយមិនគិតថ្លៃ។ អតិថិជនសាជីវកម្មអាចធ្វើការទូទាត់ PPWSA និង EDC តាមអ៊ីនធើណែតភ្លាមៗពី smartBiz ដោយមិនចាំបាច់ទៅដល់ទីកន្លែង សូម្បីតែសាខាដែលនៅជិតពួកគេបំផុត។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី៣ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៨.៥១៥ | ៧.៣០៨ |
| ឥណទានដុលសរុប (លានរៀល) | ៣.២៣០.០៩២ | ៣.០៣៧.៩៣១ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៤៣.២០០ | ១៥៨.៥៦១ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ៣.០២២.២៨៦ | ៣.០៣២.៥៥៦ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៨២ | ៤៤៥ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៧០ | ៦៨ |
| ចំនួនម៉ាស៊ីនទូទាត់ | ២៣៨ | ២៣៨ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ឆ្នាំ២០២២ | | ត្រីមាសទី៣ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៨.៩៥៨ | ៩៥,៨៤ | ៧៥.២៧៣ | ៩៥,៨២ |
| ២ | ចំណូលកម្រៃ និងជើងសារ | ១.៨៩១ | ២,៣០ | ៣.១៥៣ | ៤,០១ |
| ៣ | ចំណូលផ្សេងៗ | ១.៥៣៣ | ១,៨៦ | ១៣៤ | ០,១៧ |
| **ចំណូលសរុប** | | **៨២.៣៨២** | **១០០** | **៧៨.៥៦១** | **១០០** |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញពាណិជ្ជ ម.ក (PPCBank)និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co., Ltd គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ឆ្នាំ២០២២ | | ត្រីមាសទី៣ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន(លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៨.៩៥៨ | ៩៥,៨៤ | ៧៥.២៧៣ | ៩៥,៨២ |
| ២ | ចំណូលកម្រៃ និងជើងសារ | ១.៨៩១ | ២,៣០ | ៣.១៥៣ | ៤,០១ |
| ៣ | ចំណូលផ្សេងៗ | ១.៥៣៣ | ១,៨៦ | ១៣៤ | ០,១៧ |
| ចំណូលសរុប | | ៨២.៣៨២ | ១០០ | ៧៨.៥៦១ | ១០០ |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលភាគច្រើនមកពីការប្រាក់ ដែលមាន ៩៦% នៃប្រាក់ចំណូលសរុបក្នុងត្រីមាសទី៣ឆ្នាំ២០២២។

## ៣. ការវិភាគគម្លាតចំណេញដុល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរៀបចំរបាយការណ៍លទ្ធផលរួមរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល ប៉ុន្តែទម្រង់របាយការណ៍នេះអាចបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុចបន្ទាប់ការវិភាគចំណេញ(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៏ចំនេញខាត | ត្រីមាសទី៣ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៧៨.៩៥៨ | ៧៥.២៧៣ | ៣.៦៨៥ | ៤,៨៩ |
| ចំណាយលើការប្រាក់ | (២៥.៩២៦) | (២៦.៧៧២) | ៨៤៦ | (៣,១៦) |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៥៣.០៣២** | **៤៨.៥០២** | **៤.៥៣១** | **៩,៣៤** |
| ចំណូលកម្រៃ និងជើងសារ | ១.៨៩១ | ៣.១៥៣ | (១.២៦២) | (៤០,០៣) |
| ចំណាយកម្រៃ និងជើងសារ | (៩៩៤) | (៨៧៦) | (១១៨) | ១៣,៤៧ |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | **៨៩៧** | **២.២៧៧** | **(១.៣៨០)** | **(៦០,៦២)** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១.៥៣៣ | ១៣៤ | ១.៣៩៩ | ១.០៤៣,០៨ |
| ចំណាយបុគ្គលិក | (៨.៣៥១) | (៨.២៤៧) | (១០៥) | ១,២៧ |
| ចំណាយប្រតិបត្តិការ | (៧.៩៦០) | (៥.៥៤៣) | (២.៤១៧) | ៤៣,៥៩ |
| ចំណាយរំលស់ | (៦.៨៧៩) | (៨.១៩២) | ១.៣១៣ | (១៦,០៣) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **៣២.២៧២** | **២៨.៩៣១** | **៣.៣៤២** | **១១,៥៥** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (៨៧៣) | (១.៣២៧) | ៤៥៤ | (៣៤,១៩) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៣១.៣៩៩** | **២៧.៦០៣** | **៣.៧៩៥** | **១៣,៧៥** |

ក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ៣១.៣៩៩លានរៀល (១៤% កើនឡើងប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០២១) ។ ការកើនឡើងនៃប្រាក់ចំណេញភាគច្រើនគឺទទួលបានមកពីការថយចុះនៃចំណាយការប្រាក់ និងការកើនឡើងនៃចំណូលពីការប្រាក់។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី៣ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣១.៣៩៩ | ២៧.៦០៣ | ៣.៧៩៥ | ១៣,៧៥ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៦.១៩៣) | (៥.៧៣១) | (៤៦២) | ៨,០៦ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | ២៥.២០៦ | ២១.៨៧២ | ៣.៣៣៤ | ១៥,២៤ |

ក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ២៥.២០៦លានរៀល ដែលបានកើនឡើង ១៥% ប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០២១ ការកើនឡើងនេះមកពីការប្រែលប្រួលដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី៣ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ២៥.២០៦ | ២១.៨៧២ | ៣.៣៣៤ | ១៥,២៤ |
| ការខាតលម្អិតផ្សេងៗ | ៣.៨១៨ | ៦៣១ | ៣.១៨៧ | ៥០៥,២៥ |
| **ប្រាក់ចំណេញលម្អិតសរុប** | ២៩.០២៤ | ២២.៥០៣ | ៦.៥២១ | ២៨,៩៨ |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកនៅលើមាត្រដ្ឋានសកលដោយសារតែការកើនឡើងនៃភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុ បានដាក់សម្ពាធលើរូបិយប័ណ្ណនៃប្រទេសដទៃទៀត។ ខណៈពេលដែលរូបិយប័ណ្ណនៃប្រទេសកំពុងរីកចម្រើនបានធ្លាក់ចុះយ៉ាងខ្លាំងធៀបនឹងប្រាក់ដុល្លារអាមេរិកនាពេលបច្ចុប្បន្ន អតិផរណាអាចពិបាកក្នុងការគ្រប់គ្រងនិងកាត់បន្ថយជាងការរំពឹងទុក ប្រសិនបើទីផ្សារការងារមានភាពតឹងតែងជាងការរំពឹងទុក ឬការរំពឹងទុកនៃអតិផរណាមិនស្ថិតស្ថេរ។ លក្ខខណ្ឌហិរញ្ញវត្ថុសកលកាន់តែតឹងតែង អាចបង្កបញ្ហាជាបំណុលនៅក្នុងទីផ្សារដែលកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ ការផ្ទុះឡើងជាថ្មីនៃ COVID-19 និងការបិទប្រទេស ក៏ដូចជាការកើនឡើងបន្ថែមទៀត

នៃវិបត្តិវិស័យអចលនទ្រព្យអាចនឹងរារាំងកំណើននេះ និងការបែងចែកភូមិសាស្ត្រនយោបាយអាចរារាំងពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការពិភពលោក។

ដូច្នេះហើយ គណៈគ្រប់គ្រងយល់ឃើញថា សកម្មភាពរបស់ក្រុម និងធនាគារអាចរងផលប៉ះពាល់ខ្លះៗ មកលើប្រតិបត្តិការរបស់ក្រុម និងធនាគារ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ខណៈពេលដែលរូបិយប័ណ្ណនៃប្រទេសកំពុងរីកចម្រើនបានធ្លាក់ចុះយ៉ាងខ្លាំងធៀបនឹងប្រាក់ដុល្លារអាមេរិកនាពេលបច្ចុប្បន្ន វាអាចមានឥទ្ធិពលលើតម្រូវការ និងការផ្គត់ផ្គង់ជាសកល។ ដូច្នេះ ដើម្បីបន្តបង្កើនផលិតផល និងសេវាកម្មរបស់ធនាគារ ធនាគារនៅតែបន្តអភិវឌ្ឍបន្ថែមទៀតឥតឈប់ឈរសម្រាប់សេវាកម្មបែបឌីជីថលរបស់ធនាគារដូចខាងក្រោម៖

- ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតនូវសេវាកម្មថ្មីមួយស្តីពី សេវាផ្ទេរប្រាក់អន្តរជាតិពីប្រទេសកូរ៉េ (ខាងត្បូង) មកកាន់ប្រទេសកម្ពុជា តាមរយៈសមាជិកបាគងទាំងអស់ ដែលធនាគារភ្នំពេញ ពាណិជ្ជ ម.ក បានសហការជាមួយធនាគារ Jeonbuk ដើម្បីអនុញ្ញាត/បើកការផ្ទេរប្រាក់ពីធនាគារ Jeonbuk ទៅកាន់សមាជិកបាគងទាំងអស់ជាមួយការទូទាត់ភ្លាមៗ។ តបតាមការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ក្នុងអតិថិជនម្នាក់អាចផ្ទេរប្រាក់បានរហូតដល់ ១០,០០០ ដុល្លារក្នុងមួយថ្ងៃ តាមរយៈសេវាកម្មនេះ ។ ការផ្ទេរប្រាក់អាចធ្វើឡើងពីធនាគារចល័តរបស់ Jeonbuk Mobile Banking សេវាធនាគារតាមអ៊ីនធើណែត និង តាមរយៈសាខាផ្ទាល់។ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក គឺជាធនាគារដំបូងគេនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានការសហការជាមួយធនាគារ Jeonbuk ក្នុងការអនុញ្ញាតអោយមានការផ្ទេរប្រាក់ពីប្រទេសកូរ៉េខាងត្បូងជាមួយការទូទាត់ភ្លាមៗទៅកាន់សមាជិកបាគង ទាំងអស់នៅក្នុងប្រទេសកម្ពុជាតាមរយៈសេវាផ្ទេរប្រាក់បាគង។
- សេវាធនាគារចល័តរបស់ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់បញ្ចូលនិងដាក់អោយអនុវត្តនូវមុខងារបន្ថែមរបស់ យេអេចយូអរ ដែលអាចទាញយកជារូបភាពយេអេចយូអរ សម្រាប់ប្រើប្រាស់ក្នុងការទូទាត់រវាងគណនីនៃធនាគារពីរផ្សេងគ្នាតាមរយៈយូអរដោយភាគីទាំងសងខាង

មិនចាំបាច់ជួបគ្នាផ្ទាល់ដើម្បីធ្វើការទូទាត់នោះទេ។ សម្រាប់ទាំងអ្នកប្រើប្រាស់ សេវាធនាគារចល័ត និងទាំងម្ចាស់អាជីវកម្ម គឺអាចទាញយក យេអេចឃ្យូអររបស់ធនាគារយើងដើម្បីចែករំលែកបានយ៉ាងងាយស្រួល។

- ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រេចបានកាន់តែប្រសើរឡើងនូវការដាក់អោយប្រើប្រាស់សេវាប្រមូលការទូទាត់តាមគណនីនិម្មិត ដើម្បីទទួលបានការទូទាត់ភ្លាមៗតាមរយៈបាគង។ អតិថិជន និងសហគ្រាសដែលប្រើប្រាស់គណនីនិម្មិតរបស់យើង ជាការប្រមូលការទូទាត់សម្រាប់អាជីវកម្មរបស់ពួកគេអាចទទួលបានការទូទាត់ពីសមាជិកបាគងជាច្រើន ។
- នាខែកញ្ញា ឆ្នាំ២០២២ ការទូទាត់វិក្កយប័ត្របង់ទឹក PPWSA និង ការទូទាត់វិក្កយប័ត្របង់ភ្លើង EDC បានដាក់អោយដំណើរការតាមប្រព័ន្ធអ៊ីនធើណែត និងដោយមិនគិតថ្លៃ។ អតិថិជនសាជីវកម្មអាចធ្វើការទូទាត់ PPWSA និង EDC តាមអ៊ីនធើណែតភ្លាមៗពី smartBiz ដោយមិនចាំបាច់ទៅដល់ទីកន្លែង សូម្បីតែសាខាដែលនៅជិតពួកគេបំផុត។

## ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

## ៣. ការវិភាគលើពន្ធ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងកាតព្វកិច្ចពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "**មាស**" ពីអគ្គនាយដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២២ និង២០២៣។

## ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សេដ្ឋកិច្ចពិភពលោកកំពុងមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំពេលពីការកើនឡើងនៃអតិផរណា អាចនឹងប៉ះពាល់ដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ធនាគារភ្នំពេញពាណិជ្ជ ម.ក មានការកើនឡើងនៃចំណូលដែលមានចំណូលការប្រាក់សុទ្ធសរុប ៥៣.០៣២លានរៀលដែលស្មើនឹងការកើនឡើង ៩.៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

អតិផរណាមានកម្រិតដល់ ៧.៨៥% ក្នុងខែមិថុនា ២០២២ ដែលប្រៀបធៀបទៅ ៧.១៧% ធៀបនឹងខែមុន ដោយសារកំណើនថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងម្ហូបអាហារ។ ជាមួយអត្រាអតិផរណានេះមិនមានផលប៉ះពាល់ណាមួយជាសារវន្តមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារនៅឡើយទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

ដើម្បីឆ្លើយតបទៅនឹងបរិបទនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ក៏ដូចជាការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធ Blockchain សម្រាប់ប្រតិបត្តិការ NCD ដើម្បីធានាបាននូវភាពត្រឹមត្រូវ សុវត្ថិភាព និងភាពងាយស្រួលជាមួយនឹងការបន្ថែមមុខងារថ្មីបន្ថែមទៀត។ មុខងារដែលអនុញ្ញាតឱ្យធនាគារ និងស្ថាប័នហិរញ្ញវត្ថុអាចធ្វើប្រតិបត្តិការដូចជា ការជួញដូរ ការដាក់បញ្ចាំ ការគ្រប់គ្រងផលប័ត្រ និងការទាញយករបាយការណ៍។

នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅតែតម្រូវឲ្យបន្តរៀបចំរបាយការណ៍ត្រីមាស ស្តីពីការវាយតម្លៃការធ្វើចំណាត់ថ្នាក់ និងការធ្វើសំវិធានធនចំពោះឥណទានរៀបចំឡើងវិញ និងសមត្ថភាពសងរបស់អតិថិជនស្របតាមគំរូរបាយការណ៍ដូចមានជូនភ្ជាប់នឹងសារាចរណែនាំលេខ ធ៧-០២១-០០២ ស.រ.ច.ណ.ន ចុះថ្ងៃទី២៤ខែមិថុនាឆ្នាំ២០២១ ស្តីពីការវាយតម្លៃ ការធ្វើចំណាត់ថ្នាក់ និងការធ្វើសំវិធានធនចំពោះឥណទានរៀបចំឡើងវិញហើយបន្តផ្ញើរបាយការណ៍នេះមកធនាគារជាតិនៃកម្ពុជា។

ទន្ទឹមនេះ គ្រឹះស្ថានត្រូវបន្តធ្វើស្រ្តេសតេស្ត ជាក់លាក់លើសំពៀតឥណទានរៀបចំឡើងវិញយ៉ាងហោចណាស់ឲ្យបាន៣(បី)សេណារីយ៉ូ លើកម្រិតមូលដ្ឋាន មធ្យម និងធ្ងន់ធ្ងរ និងត្រូវផ្ញើលទ្ធផលនៃការធ្វើស្រ្តេសតេស្តនិងវិធានការដោះស្រាយប្រចាំត្រីមាសជូន ធនាគារជាតិនៃកម្ពុជា។

ដោយឡែកគ្រឹះស្ថានត្រូវបន្តកាតព្វកិច្ចរាយការណ៍ប្រចាំខែ ស្របតាមសារាចរណែនាំលេខ ធ៧-០២០-០០១ ស.រ.ណ.ន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីឥណទានរៀបចំឡើងវិញអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលរបស់វីរុសកូវីដ១៩ និងតាមលិខិតជូនដំណឹងលេខ ធ៧-០២២-១៦៧ ឆ.តចុះចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ស្តីពី ករណីបំពេញកាតព្វកិច្ចរាយការណ៍ថ្មីក្នុងអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលរបស់វីរុសកូវីដ១៩ដោយបែងចែកតាមវិស័យ។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២

បានអាន និងឯកភាព

លោក YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank